## អត្ថបទរៀនអាន ទី៣

ពីឈ្មោះក្រុង ព្រៃនគរ មកជាក្រុង ហូជីមិញ

ព្រៃនគរក្លាយមកពីពាក្យដើមថាព្រៃគបូមកពីពាក្យថាភាគខាងត្បូងនៃព្រះរាជនគរ ព្រោះនៅក្នុងគ.ស. ១៦២០ ព្រះរាជាប្រទេសយួនបានដង្ហែព្រះរាជបុត្រីមួយព្រះអង្គប្រកបដោយរូបឆោមលោមពណ៌មកថ្វាយព្រះជ័យជេដ្ឋា ទី២ ជាព្រះរាជមេត្រី ។ ព្រះជ័យជេដ្ឋាក៏ទ្រង់ព្រមលើកឡើងជាព្រះមហេសី ។

ព្រះរាជាយួនមានព្រះរាជសារមកដល់ព្រះជ័យជេដ្ឋា ទី២ សុំឲ្យយួនចូលមកតាំងនៅរកស៊ីនៅជាយខាងត្បូងនៃព្រះរាជនគរ ហើយសុំផ្នែកក្រសួងគយផង ដើម្បីទ្រទ្រង់ជាតិយួននៅទីនោះ ។ ព្រះជ័យជេដ្ឋាក៏ទ្រង់យល់ព្រម ។

ឆ្លៀតឱកាសក្នុងសម័យវឹកវរទាំងខាងក្នុងប្រទេសទាំងខាងក្រៅប្រទេស រវាងយួននិងសៀម បារាំងក៏ចូលមកយកដែនដីព្រៃនគរនោះជាអាណានិគម ហើយហៅថា កូសាំងស៊ីន (១៨៦៧) ។ បារាំងជាន់បានរហូតដល់នគរកម្ពុជាលាវ ដែលត្រូវតែក្លាយជាអាណានិគម ។

ក្រោយមកសង្គ្រាមលោក ទី២ បានផ្ទុះឡើងនគរអាណានិគមនេះបានបង្កើតចលនាបះបោរប្រឆាំងនឹងអ្នកអាណានិគមនិយមហើយបារាំងក៏ប្រគល់ឯករាជ្យពេញទីមកឲ្យប្រទេសទាំងនោះនៅឆ្នាំ ១៩៥៤ ។ ដែនដីកូសាំងស៊ីនត្រូវបានប្រកាសទៅជាវៀតណាមខាងត្បូងដាច់ស្រឡះពីនគរកម្ពុជា ។

វៀតណាមដែលចែកជាពីរ ភាគខាងជើងក្រុងហាណូយជារដ្ឋធានីបានបន្តនយោបាយវាតទឹកដីទៅខាងត្បូងដោយបង្កើតជារណសិរ្សសេរីកាជាតិវៀតណាមហៅថា វៀតកុង ប្រឆាំងនឹងរបបសេរីនិយមភាគខាងត្បូងដែលមានសហរដ្ឋអាមេរិកគាំទ្រ ។

លុះឆ្នាំ ១៩៧៥ សហរដ្ឋបានដកខ្លួនចេញពីសង្គ្រាមឥណ្ឌូចិន វៀតណាមខាងជើងក៏បានចូលកាន់កាប់ត្រួតត្រាវៀតណាមខាងត្បូងផ្លាស់ឈ្មោះទីក្រុង

ព្រៃនគរឬសៃហ្គុង នោះទៅជាក្រុង ហូជីមិញ ដើម្បីរំលឹកដល់ជោគជ័យនៃគំនិត ពង្រីកទឹកដីរបស់ប្រធានាធិបតី ហូ ជីមិញ ។